# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក

*(ពីមុនជា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់)*

របាយការណ៍ហិរញ្ញវត្ថុសង្ខេបក្នុងគ្រាដែលមិនបានធ្វើសវនកម្ម
ដែលត្រូវបានរៀបចំឡើងដោយអនុលោមទៅតាមស្តង់ដារគណនេយ្យអន្តរជាតិ
នៃកម្ពុជាលេខ 34 *ការរាយការណ៍ហិរញ្ញវត្ថុក្នុងគ្រា*

នាថ្ងៃទី30 ខែកញ្ញា ឆ្នាំ2020 និងសម្រាប់ការិយបរិច្ឆេទបញ្ចប់ 9ខែ

## គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក

*(ពីមុនជា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់)*

## មាតិកា


| | |
|---|---|
| | *ទំព័រ* |
| របាយការណ៍របស់ក្រុមប្រឹក្សាភិបាល | 1-6 |
| របាយការណ៍ហិរញ្ញវត្ថុសង្ខេបក្នុងគ្រាដែលមិនបានធ្វើសវនកម្ម | |
| របាយការណ៍ស្តីពីការពិនិត្យលើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបក្នុងគ្រា | 7 |
| របាយការណ៍ស្ថានភាពហិរញ្ញវត្ថុសង្ខេបក្នុងគ្រាមិនបានធ្វើសវនកម្ម | 8 |
| របាយការណ៍លទ្ធផលពេញលេញសង្ខេបក្នុងគ្រាមិនបានធ្វើសវនកម្ម | 9 - 10 |
| របាយការណ៍បម្រែបម្រួលមូលធនសង្ខេបក្នុងគ្រាមិនបានធ្វើសវនកម្ម | 11 |
| របាយការណ៍លំហូរសាច់ប្រាក់សង្ខេបក្នុងគ្រាមិនបានធ្វើសវនកម្ម | 12 |
| កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបក្នុងគ្រាមិនបានធ្វើសវនកម្ម | 13 – 50 |

## របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលរបស់ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក *(ពីមុនជា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់)* ("ក្រុមហ៊ុន") សូមធ្វើការបង្ហាញជូននូវរបាយការណ៍របស់ខ្លួន និងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបក្នុងគ្រារបស់ក្រុមហ៊ុនដែលមិនបានធ្វើសវនកម្ម នាថ្ងៃទី30 ខែកញ្ញា ឆ្នាំ2020 និងសម្រាប់ការិយបរិច្ឆេទបញ្ចប់ 3ខែ និង 9ខែ។

## ព័ត៌មានអំពីក្រុមហ៊ុន

ក្រុមហ៊ុនត្រូវបានបង្កើតឡើង និងចុះបញ្ជីពាណិជ្ជកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា ជាមួយក្រសួងពាណិជ្ជកម្ម ជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ក្រោមបញ្ជីពាណិជ្ជកម្មលេខ 00001157 ចុះថ្ងៃទី19 ខែកញ្ញា ឆ្នាំ2011 និងដែលបានចុះបញ្ជីសារជាថ្មី នាថ្ងៃទី28 ខែមេសា ឆ្នាំ2016។

ធនាគារជាតិនៃកម្ពុជា បានផ្តល់អាជ្ញាប័ណ្ណមីក្រូហិរញ្ញវត្ថុឲ្យក្រុមហ៊ុន ដែលមានសុពលភាព ចាប់ពីថ្ងៃទី14 ខែធ្នូ ឆ្នាំ2007។ លើសពីនេះទៅទៀតក្រុមហ៊ុនបានទទួលអាជ្ញាប័ណ្ណ ពីធនាគារជាតិនៃកម្ពុជាដើម្បីធ្វើអាជីវកម្មទទួលប្រាក់បញ្ញើ នៅថ្ងៃទី27 ខែសីហា ឆ្នាំ2010 និងការអនុញ្ញាតឲ្យដំណើរការម៉ាស៊ីនដក-ដាក់ប្រាក់ស្វ័យប្រវត្តិ និង សេវាកម្មបង់ប្រាក់តាមម៉ាស៊ីនឆូតកាតនៅថ្ងៃទី01 ខែធ្នូ ឆ្នាំ2011។

ស្នាក់ការចុះបញ្ជីរបស់ក្រុមហ៊ុន មានទីតាំងនៅអគារលេខ 212 ផ្លូវលេខ 271 សង្កាត់ទួលទំពូង2 ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

## លទ្ធផលហិរញ្ញវត្ថុ

លទ្ធផលហិរញ្ញវត្ថុរបស់ក្រុមហ៊ុនសម្រាប់ការិយបរិច្ឆេទបញ្ចប់ 9ខែ នាថ្ងៃទី30 ខែកញ្ញា ឆ្នាំ2020 ត្រូវបានបង្ហាញនៅក្នុងរបាយការណ៍លទ្ធផលពេញលេញ។

## ភាគលាភ

គ្មានការបែងចែកភាគលាភត្រូវបានប្រកាស ឬ ទូទាត់ក្នុងការិយបរិច្ឆេទទេ ហើយក្រុមប្រឹក្សាភិបាលមិនផ្តល់អនុសាសន៍អោយមានការទូទាត់ភាគលាភ នាកាលបរិច្ឆេទនៃរបាយការណ៍នេះទេ។

## ទុនបម្រុង និងសំវិធានធន

ពុំមានការប្រែប្រួលជាសារវន្តលើទុនបម្រុង និងសំវិធានធននៅក្នុងការិយបរិច្ឆេទនេះទេ ក្រៅពីការបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបក្នុងគ្រាដែលមិនបានធ្វើសវនកម្មនេះ។

## ការខាតបង់ដែលបានរំពឹងទុកទៅលើឥណទាន និងបុរេប្រទានទៅអតិថិជន

មុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុសង្ខេបក្នុងគ្រាដែលមិនបានធ្វើសវនកម្មរបស់ក្រុមហ៊ុនត្រូវបានរៀបចំ ក្រុមប្រឹក្សាភិបាលបានចាត់វិធានការសមស្របដើម្បីបញ្ជាក់ថា វិធានការទាក់ទងទៅនឹងការលុបចេញពីបញ្ជីនូវឥណទានអាក្រក់ ត្រូវបានលុបចេញពីបញ្ជី ហើយសំវិធានធនត្រូវបានធ្វើឡើងយ៉ាងគ្រប់គ្រាន់សម្រាប់ការខាតបង់ដែលបានរំពឹងទុកទៅលើឥណទាន។

## គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក

*(ពីមុនជា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់)*

**របាយការណ៍របស់ក្រុមប្រឹក្សាភិបាល** (តពីទំព័រមុន)

### ការខាតបង់ដែលបានរំពឹងទុកទៅលើឥណទានផ្តល់ដល់អតិថិជន (តពីទំព័រមុន)

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយ ដែលអាចនឹងបណ្តាលឲ្យចំនួននៃការលុបចេញពីបញ្ជី ទៅលើឥណទានអាក្រក់ ឬចំនួននៃការធ្វើសំវិធានធនសម្រាប់ការខាតបង់ដែលបានរំពឹងទុក នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបក្នុងគ្រា របស់ក្រុមហ៊ុនដែលមិនបានធ្វើសវនកម្ម មានចំនួនមិនគ្រប់គ្រាន់ជាសារវន្តនោះឡើយ។

### ទ្រព្យសកម្មចរន្ត

មុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុសង្ខេបក្នុងគ្រាដែលមិនបានធ្វើសវនកម្មរបស់ក្រុមហ៊ុន ត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការ ដែលមានមូលដ្ឋានសមហេតុផលដើម្បីបញ្ជាក់ថាបណ្តាទ្រព្យសកម្មក្រៅពីបំណុល ដែលសន្និដ្ឋានថាមិនអាចប្រមូលមកវិញតាមតម្លៃដែលបានកត់ត្រានៅក្នុងបញ្ជីនៅក្នុងប្រតិបត្តិការអាជីវកម្មធម្មតាត្រូវបាន កាត់បន្ថយឲ្យនៅស្មើនឹងតម្លៃដែលរំពឹងថានឹងអាចប្រមូលបានជាក់ស្តែង។

នាថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលនឹងប៉ះពាល់ដល់ការកំណត់តម្លៃទ្រព្យសកម្ម នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបក្នុងគ្រាដែលមិនបានធ្វើសវនកម្មរបស់ក្រុមហ៊ុន មានភាពពុំត្រឹមត្រូវនោះទេ។

### វិធីសាស្រ្តនៃការវាយតម្លៃ

នាថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយ ដែលបានកើតឡើងហើយប៉ះពាល់ដល់ការអនុវត្តវិធីសាស្រ្តដែលមានកន្លងមក ក្នុងការវាយតម្លៃទ្រព្យសកម្ម និងបំណុលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបក្នុងគ្រាដែលមិនបានធ្វើសវនកម្មរបស់ក្រុមហ៊ុន ថាមានភាពមិនត្រឹមត្រូវ ឬ មិនសមស្របនោះទេ។

### បំណុលយថាភាព និងបំណុលផ្សេងៗ

នាថ្ងៃចេញរបាយការណ៍នេះ ៖

- ពុំមានការផ្លាស់ប្តូរលើទ្រព្យសកម្មណាមួយ របស់ក្រុមហ៊ុនដែលកើតឡើងក្នុងការធានាចំពោះបំណុលរបស់បុគ្គលណាម្នាក់ឡើយ ចាប់តាំងពីថ្ងៃចុងការិយបរិច្ឆេទនោះទេ និង
- ពុំមានបំណុលយថាហេតុណាមួយដែលកើតមានឡើងចំពោះក្រុមហ៊ុន ចាប់តាំងពីចុងការិយបរិច្ឆេទមក ក្រៅអំពីប្រតិបត្តិការអាជីវកម្មធម្មតារបស់ក្រុមហ៊ុន។

ក្រុមប្រឹក្សាភិបាលយល់ឃើញថា ពុំមានបំណុលយថាហេតុ ឬបំណុលផ្សេងៗទៀតរបស់ក្រុមហ៊ុនដែលត្រូវបានទាមទារឲ្យសង ឬអាចនឹងទាមទារឲ្យសងក្នុងអំឡុងពេលមួយឆ្នាំ បន្ទាប់ពីថ្ងៃបញ្ចប់ការិយបរិច្ឆេទ ដែលនឹងមានផលប៉ះពាល់ជាសារវន្តដល់លទ្ធភាពរបស់ក្រុមហ៊ុន ក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួននៅពេលដែលដល់ថ្ងៃកំណត់ឡើយ។

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក
*(ពីមុនជា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់)*

## របាយការណ៍របស់ក្រុមប្រឹក្សាភិបាល (តពីទំព័រមុន)

### ការផ្លាស់ប្តូរនៃហេតុការណ៍

នាការិយបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយ ដែលមិនបានកើតឡើងនៅក្នុងរបាយការណ៍នេះ ឬក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ដែលនឹងបណ្តាលឲ្យមានតួលេខណាមួយដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុដែលមិនបានធ្វើសវនកម្ម មានភាពមិនត្រឹមត្រូវនោះទេ។

នៅក្នុងមតិយោបល់របស់ក្រុមប្រឹក្សាភិបាល លទ្ធផលនៃប្រតិបត្តិការរបស់ក្រុមហ៊ុន ក្នុងការិយបរិច្ឆេទរបាយការណ៍ហិរញ្ញវត្ថុនេះ មិនមានផលប៉ះពាល់ជាសារវន្តដោយសកម្មភាពប្រតិបត្តិការ ឬ ព្រឹត្តិការណ៍ណាមួយដែលមានលក្ខណៈជាសារវន្ត និងមិនប្រក្រតីនោះទេ។

ក្រុមប្រឹក្សាភិបាលក៏មានមតិផងដែរថា នៅក្នុងចន្លោះពេលចាប់ពីការិយបរិច្ឆេទបញ្ចប់ដល់ការិយបរិច្ឆេទនៃរបាយការណ៍នេះ ពុំមានចំណាត់ថ្នាក់សកម្មភាពប្រតិបត្តិការ ឬ ព្រឹត្តិការណ៍ណាមួយដែលមានលក្ខណៈជាសារវន្ត និង កើតមានឡើងមិនប្រក្រតី ដែលអាចនាំឲ្យប៉ះពាល់ដល់លទ្ធផលនៃប្រតិបត្តិការរបស់ក្រុមហ៊ុន ក្នុងការិយបរិច្ឆេទដែលរបាយការណ៍នេះបានរៀបចំឡើងនោះទេ។

### ព្រឹត្តិការណ៍ក្រោយការិយបរិច្ឆេទនៃរបាយការណ៍

មិនមានព្រឹត្តិការណ៍គួរឲ្យកត់សម្គាល់ណាមួយកើតឡើង ក្រោយកាលបរិច្ឆេទរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុដែលតម្រូវឲ្យមានការបង្ហាញ ឬកែតម្រូវ ក្រៅពីអ្វីដែលបានបង្ហាញរួចហើយនៅក្នុងកំណត់សំគាល់ទៅលើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបក្នុងគ្រាដែលមិនបានធ្វើសវនកម្ម។

### ក្រុមប្រឹក្សាភិបាល

សមាជិកក្រុមប្រឹក្សាភិបាលដែលមានតំណែង នៅក្នុងការិយបរិច្ឆេទ និងនាកាលបរិច្ឆេទនៃរបាយការណ៍នេះរួមមាន៖

| *ឈ្មោះ* | *មុខងារ* | *ការិយបរិច្ឆេទតែងតាំង* |
|---|---|---|
| លោក Chan Tze Ching Ignatius | ប្រធានក្រុមប្រឹក្សាភិបាល | ថ្ងៃទី10 ខែមីនា ឆ្នាំ2017<br>(លាលែង នៅថ្ងៃទី10 ខែមេសា ឆ្នាំ2020) |
| លោក Kwi Sang JUN | ប្រធានក្រុមប្រឹក្សាភិបាល | ថ្ងៃទី10 ខែមេសា ឆ្នាំ2020 |
| លោក Hak Soo KIM | អភិបាល | ថ្ងៃទី10 ខែមេសា ឆ្នាំ2020 |
| លោក Ji Kyu JANG | អភិបាល | ថ្ងៃទី10 ខែមេសា ឆ្នាំ2020 |
| លោក Ishara Chinthaka Nanayakkara | អភិបាល | ថ្ងៃទី10 ខែមីនា ឆ្នាំ2017 |
| លោក ស៊ឹម សេនាជាតិ | អភិបាល | ថ្ងៃទី10 ខែមីនា ឆ្នាំ2017 |
| លោក Yuen Wai Hung Peter | អភិបាល | ថ្ងៃទី10 ខែមីនា ឆ្នាំ2017<br>(លាលែង នៅថ្ងៃទី10 ខែមេសា ឆ្នាំ2020) |
| លោក Thilakaratne Don Manuwelge Don Krishan | អភិបាល | ថ្ងៃទី10 ខែមេសា ឆ្នាំ2018<br>(លាលែង នៅថ្ងៃទី10 ខែមេសា ឆ្នាំ2020) |
| លោក Minki Brian HONG | អភិបាល | ថ្ងៃទី10 ខែមីនា ឆ្នាំ2017 |
| លោក Hwan Kook KIM | អភិបាលឯករាជ្យ | ថ្ងៃទី10 ខែមេសាឆ្នាំ2020 |
| លោក Hana LEE | អភិបាលឯករាជ្យ | ថ្ងៃទី10 ខែមេសា ឆ្នាំ2020 |
| លោក បៃល សក្តិភក្តី | អភិបាលឯករាជ្យ | ថ្ងៃទី10 ខែមេសា ឆ្នាំ2020 |
| លោក Hiep Van Vo | អភិបាលឯករាជ្យ | ថ្ងៃទី10 ខែមីនា ឆ្នាំ2017<br>(លាលែង នៅថ្ងៃទី10 ខែមេសា ឆ្នាំ2020) |

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក
*(ពីមុនជា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់)*

**របាយការណ៍របស់ក្រុមប្រឹក្សាភិបាល** (តពីទំព័រមុន)

## គណៈគ្រប់គ្រងសំខាន់ៗ

សមាជិកគណៈគ្រប់គ្រងសំខាន់ៗ ដែលមានតំណែងនៅក្នុងការិយបរិច្ឆេទ និងនាកាលបរិច្ឆេទនៃរបាយការណ៍នេះរួមមាន៖

| *ឈ្មោះ* | *មុខងារ* | *ការិយបរិច្ឆេទតែងតាំង* |
|---|---|---|
| លោក ស៊ីម សេនាជាតិ | ប្រធាននាយកប្រតិបត្តិ | ថ្ងៃទី17 ខែវិច្ឆិកា ឆ្នាំ2003 |
| លោក អ៊ុំ សូផន | អនុប្រធាននាយកប្រតិបត្តិទទួលបន្ទុកហិរញ្ញវត្ថុ | ថ្ងៃទី01 ខែមិថុនា ឆ្នាំ2008 |
| លោក អ៊ុំ សមអឿន | អនុប្រធាននាយកប្រតិបត្តិទទួលបន្ទុកប្រតិបត្តិការ | ថ្ងៃទី10 ខែមេសា ឆ្នាំ2007 |
| លោក នាង សុខឃីម | អនុប្រធាននាយកប្រតិបត្តិទទួលបន្ទុកគ្រប់គ្រងអាជីវកម្ម | ថ្ងៃទី10 ខែវិច្ឆិកា ឆ្នាំ2010 |
| លោក សាយ សូនី | អនុប្រធាននាយកប្រតិបត្តិទទួលបន្ទុកគ្រប់គ្រងទីផ្សារ | ថ្ងៃទី10 ខែវិច្ឆិកា ឆ្នាំ2010 |
| លោក ជួប វាសនា | អនុប្រធាននាយកប្រតិបត្តិទទួលបន្ទុកធនធានមនុស្ស | ថ្ងៃទី05 ខែកុម្ភៈ ឆ្នាំ2020 |
| លោក ជា ហាង | អនុប្រធាននាយកប្រតិបត្តិទទួលបន្ទុកផែនការយុទ្ធសាស្ត្រ និងអាជីវកម្ម | ថ្ងៃទី24 ខែកុម្ភៈ ឆ្នាំ2020 |

## សវនករ

ក្រុមហ៊ុនសវនកម្មឯករាជ្យ Ernst & Young (Cambodia) Ltd. គឺជាសវនកររបស់ក្រុមហ៊ុន។

## ភាគហ៊ុនកាន់កាប់របស់ក្រុមប្រឹក្សាភិបាល

មិនមានសមាជិកក្រុមប្រឹក្សាភិបាលណាម្នាក់ កាន់កាប់ភាគហ៊ុនដោយផ្ទាល់របស់ក្រុមហ៊ុននោះទេ។

## អត្ថប្រយោជន៍របស់ក្រុមប្រឹក្សាភិបាល

ក្នុងអំឡុងពេល និងនាចុងការិយបរិច្ឆេទបញ្ចប់នេះពុំមានកិច្ចព្រមព្រៀងណាមួយដែលក្នុងនោះក្រុមហ៊ុនជាភាគីម្ខាង អាចបង្កលទ្ធភាពដល់សមាជិកក្រុមប្រឹក្សាភិបាលណាម្នាក់ ឲ្យទទួលបាននូវអត្ថប្រយោជន៍តាមមធ្យោបាយផ្សេងៗ ដូចជាការទិញភាគហ៊ុន ឬ ប័ណ្ណបំណុលរបស់ក្រុមហ៊ុន ឬរបស់សាជីវកម្មដទៃឡើយ។

ពុំមានសមាជិកក្រុមប្រឹក្សាភិបាលណាម្នាក់បានទទួលឬមានសិទ្ធិ បាននូវអត្ថប្រយោជន៍ណាមួយ តាមរយៈការចុះកិច្ចសន្យាធ្វើឡើងដោយក្រុមហ៊ុន ជាមួយក្រុមហ៊ុនដែលសមាជិកក្រុមប្រឹក្សាភិបាលនោះជាសមាជិក ឬក៏ជាមួយក្រុមហ៊ុនណាមួយដែលក្រុមប្រឹក្សាភិបាលនោះ មានផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុជាសារវន្តឡើយ លើកលែងតែបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបក្នុងគ្រាដែលមិនបានធ្វើសវនកម្មនេះ។

## គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក
*(ពីមុនជា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់)*

**របាយការណ៍របស់ក្រុមប្រឹក្សាភិបាល** (តពីទំព័រមុន)

### របាយការណ៍ស្តីពីការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលចំពោះរបាយការណ៍ហិរញ្ញវត្ថុសង្ខេបក្នុងគ្រាដែលមិនបានធ្វើសវនកម្ម

ក្រុមប្រឹក្សាភិបាល ជាអ្នកទទួលខុសត្រូវក្នុងការបញ្ជាក់ថារបាយការណ៍ហិរញ្ញវត្ថុសង្ខេបក្នុងគ្រាដែលមិនបានធ្វើសវនកម្ម នៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន នាថ្ងៃទី30 ខែកញ្ញា ឆ្នាំ2020 និងសម្រាប់ការិយបរិច្ឆេទបញ្ចប់ 3ខែ និង 9ខែ ដែលត្រូវបានរៀបចំឡើងយ៉ាងត្រឹមត្រូវ ដើម្បីបង្ហាញនូវទិដ្ឋភាពពិតប្រាកដ ដោយអនុលោមទៅតាមស្តង់ដារគណនេយ្យអន្តរជាតិនៃកម្ពុជាលេខ 34 *ការរាយការណ៍ហិរញ្ញវត្ថុក្នុងគ្រា* ("CIAS 34")។

ក្រុមប្រឹក្សាភិបាល ត្រួតពិនិត្យលើការរៀបចំរបាយការណ៍ហិរញ្ញវត្ថុសង្ខេបក្នុងគ្រាដែលមិនបានធ្វើសវនកម្មរបស់គណៈគ្រប់គ្រង ដែលត្រូវបានតម្រូវឲ្យ៖

- អនុម័តនូវគោលនយោបាយគណនេយ្យ សមស្របដែលផ្អែកលើការវិនិច្ឆ័យ និងការប៉ាន់ស្មានយ៉ាងសមហេតុផល និងប្រកបដោយការប្រុងប្រយ័ត្ន ហើយត្រូវអនុវត្តគោលនយោបាយទាំងនេះជាអចិន្ត្រៃយ៍។
- អនុលោមតាម តម្រូវការលាតត្រដាងជាចាំបាច់ និងការណែនាំផ្សេងៗ ដែលចេញផ្សាយដោយ CIAS 34 ឬប្រសិនបើមានគម្លាតនៃការអនុវត្តបទបញ្ញត្តិ និងគោលការណ៍ណែនាំ ហើយនឹងស្តង់ដារដើម្បីជាប្រយោជន៍ដល់ការបង្ហាញនូវភាពពិត និងត្រឹមត្រូវរបស់របាយការណ៍ហិរញ្ញវត្ថុនោះ គម្លាតទាំងនោះគួរតែត្រូវបានលាតត្រដាងព័ត៌មានពន្យល់ និងកំណត់បរិមាណ ក្នុងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបក្នុងគ្រាដែលមិនបានធ្វើសវនកម្ម ។
- រក្សាទុកនូវបញ្ជីគណនេយ្យឲ្យបានគ្រប់គ្រាន់ និងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងឲ្យមានប្រសិទ្ធភាព។
- រៀបចំរបាយការណ៍ហិរញ្ញវត្ថុសង្ខេបក្នុងគ្រាដែលមិនបានធ្វើសវនកម្ម ដោយផ្អែកលើមូលដ្ឋាននិរន្តរភាពនៃដំណើរការអាជីវកម្ម លើកលែងតែក្នុងករណីមិនសមរម្យក្នុងការសន្មតថាក្រុមហ៊ុន នឹងបន្តធ្វើប្រតិបត្តិការអាជីវកម្មរបស់ខ្លួននាពេលអនាគត។
- បង្កើតគោលការណ៍ជារួមសម្រាប់ក្រុមហ៊ុនអនុម័តរាល់សេចក្តីសម្រេចចិត្ត និងសកម្មភាពទាំងឡាយដោយគណៈគ្រប់គ្រង ដែលមានឥទ្ធិពលជាសារវន្តលើប្រតិបត្តិការអាជីវកម្ម និងលទ្ធផលនៃប្រតិបត្តិការរបស់ក្រុមហ៊ុន ហើយនឹងត្រូវធានាថាគោលនយោបាយ និងការសម្រេចចិត្តទាំងអស់នោះត្រូវបានឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវក្នុងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបក្នុងគ្រាដែលមិនបានធ្វើសវនកម្ម។

គណៈគ្រប់គ្រង ត្រូវទទួលខុសត្រូវរក្សាទុកបញ្ជីគណនេយ្យឲ្យបានត្រឹមត្រូវ ដែលបង្ហាញពីស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន និងដើម្បីធានាបានថាបញ្ជីគណនេយ្យត្រូវគោរពតាមប្រព័ន្ធគណនេយ្យដែលបានចុះបញ្ជី។ គណៈគ្រប់គ្រងក៏ទទួលខុសត្រូវផងដែរចំពោះការការពារទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន និងត្រូវចាត់វិធានការសមស្រប ដើម្បីទប់ស្កាត់ និងស្វែងរកការក្លែងបន្លំ និងភាពមិនប្រក្រតី។

ក្រុមប្រឹក្សាភិបាល បានអះអាងថាក្រុមហ៊ុនបានអនុវត្តតាមលក្ខខណ្ឌតម្រូវការចាំបាច់នានា ដែលបានបញ្ជាក់ខាងលើ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុសង្ខេបក្នុងគ្រាដែលមិនបានធ្វើសវនកម្ម។

## **គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក**

*(ពីមុនជា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់)*

**របាយការណ៍របស់ក្រុមប្រឹក្សាភិបាល** (តពីទំព័រមុន)

### **ការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបក្នុងគ្រាដែលមិនបានធ្វើសវនកម្ម**

យើងខ្ញុំ បានអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបក្នុងគ្រាដែលមិនបានធ្វើសវនកម្ម ដែលត្រូវបានរៀបចំឡើង នូវគ្រប់ទិដ្ឋភាពជាសារវន្តទាំងអស់ ដោយអនុលោមទៅតាម CIAS 34។

តំណាងក្រុមប្រឹក្សាភិបាល

លោក ស៊ីម សេនាជាតិ
អភិបាល

ធ្វើនៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី12 ខែវិច្ឆិកា ឆ្នាំ2020

Ernst & Young (Cambodia) Ltd.
5th Floor, Emerald Building
#64 Norodom Boulevard corner Street 178
Sangkat Chey Chumneah, Khan Daun Penh
12206 Phnom Penh, Kingdom of Cambodia

Tel: +855 23 860 450/451
Fax: +855 23 217 805
ey.com

Building a better working world

លេខយោង៖ 61398519/22158088

# របាយការណ៍ស្តីពីការពិនិត្យលើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបក្នុងគ្រា

## ជូនចំពោះ ៖ ភាគទុនិកនៃ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក

### *សេចក្តីផ្តើម*

យើងខ្ញុំ បានធ្វើការពិនិត្យទៅលើរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុសង្ខេបក្នុងគ្រា របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក *(ពីមុនជា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់)* ហៅកាត់ថា ("ក្រុមហ៊ុន") នាថ្ងៃទី30 ខែកញ្ញា ឆ្នាំ2020 និងរបាយការណ៍លទ្ធផលពេញលេញសង្ខេបក្នុងគ្រា របាយការណ៍បម្រែបម្រួលមូលធនសង្ខេបក្នុងគ្រា និងរបាយការណ៍លំហូរសាច់ប្រាក់សង្ខេបក្នុងគ្រាសម្រាប់ការិយបរិច្ឆេទបញ្ចប់ 9ខែ និង កំណត់សម្គាល់ពន្យល់ផ្សេងៗ។ គណៈគ្រប់គ្រងមានការទទួលខុសត្រូវក្នុងការរៀបចំ និងធ្វើបទបង្ហាញដ៏ត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុសង្ខេបក្នុងគ្រាទាំងនេះ ដោយអនុលោមតាមស្តង់ដារគណនេយ្យអន្តរជាតិនៃកម្ពុជា លេខ 34 *ការរាយការណ៍ហិរញ្ញវត្ថុក្នុងគ្រា* ("CIAS 34")។ ការទទួលខុសត្រូវរបស់យើងខ្ញុំ គឺបង្ហាញសេចក្តីសន្និដ្ឋានលើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបក្នុងគ្រាទាំងនេះ ដោយផ្អែកលើការពិនិត្យរបស់យើងខ្ញុំ។

### *វិសាលភាពនៃការពិនិត្យ*

យើងខ្ញុំ បានធ្វើការពិនិត្យ ស្របតាមស្តង់ដារអន្តរជាតិនៃកម្ពុជា ស្តីពីការចូលរួមពិនិត្យលេខ 2410 *ការពិនិត្យឡើងវិញនូវព័ត៌មានហិរញ្ញវត្ថុក្នុងគ្រាដែលអនុវត្តដោយសវនករឯករាជ្យរបស់អង្គភាព* ។ ការពិនិត្យនៃព័ត៌មានហិរញ្ញវត្ថុក្នុងគ្រារួមមាន ការសាកសួរជាចម្បងទៅបុគ្គលទទួលខុសត្រូវទាក់ទិនបញ្ហាហិរញ្ញវត្ថុនិងគណនេយ្យ និងអនុវត្តនីតិវិធីវិភាគ និងនីតិវិធីពិនិត្យផ្សេងៗទៀត។ ការពិនិត្យ មានវិសាលភាពតិចជាងការធ្វើសវនកម្ម ដែលអនុលោមតាមស្តង់ដារអន្តរជាតិនៃកម្ពុជាលើការធ្វើសវនកម្ម ហើយជាលទ្ធផលមិនអនុញ្ញាតឱ្យយើងខ្ញុំទទួលបាននូវការធានាអះអាង ដែលអាចអោយយើងខ្ញុំបានដឹងរាល់បញ្ហាសំខាន់ៗទាំងអស់ដែលអាចកំណត់បានដូចនៅក្នុងការងារសវនកម្មទេ។ ដូច្នោះ យើងខ្ញុំមិនបញ្ចេញមតិយោបល់សវនកម្មទេ។

### *សេចក្តីសន្និដ្ឋាន*

ផ្អែកលើការពិនិត្យរបស់យើងខ្ញុំ ពុំមានអ្វីដែលត្រូវផ្តោតការយកចិត្តទុកដាក់ដែលបណ្តាលឲ្យយើងខ្ញុំជឿថា របាយការណ៍ហិរញ្ញវត្ថុសង្ខេបក្នុងគ្រា មិនបានផ្តល់នូវទិដ្ឋភាពពិត និងត្រឹមត្រូវ នៃរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន នាថ្ងៃទី30 ខែកញ្ញា ឆ្នាំ2020 និងលទ្ធផលហិរញ្ញវត្ថុ ហើយនិងលំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទបញ្ចប់ 9 ខែ ដោយអនុលោមតាម CIAS 34 នោះទេ។

Maria Cristina M. Calimbas
Partner

**Ernst & Young (Cambodia) Ltd.**
ក្រុមហ៊ុនគណនេយ្យករជំនាញ និងសវនករប្រតិស្រុត

ធ្វើនៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី12 ខែវិច្ឆិកា ឆ្នាំ2020

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក

*(ពីមុនជា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់)*

## របាយការណ៍ស្ថានភាពហិរញ្ញវត្ថុសង្ខេបក្នុងគ្រាមិនបានធ្វើសវនកម្ម

នាថ្ងៃទី30 ខែកញ្ញា ឆ្នាំ2020

| | *កំណត់សម្គាល់* | *ថ្ងៃទី30 ខែកញ្ញា ឆ្នាំ2020 (មិនបានធ្វើសវនកម្ម)* | | *ថ្ងៃទី31 ខែធ្នូ ឆ្នាំ2019 (បានធ្វើសវនកម្ម)* | |
|---|---|---|---|---|---|
| | | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ 2.2)* | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ 2.2)* |
| ទ្រព្យសកម្ម | | | | | |
| សាច់ប្រាក់ក្នុងដៃ | 3 | 135,723,954 | 556,468,211 | 150,702,355 | 614,112,097 |
| សមតុល្យនៅធនាគារជាតិនៃកម្ពុជា | 4 | 358,969,410 | 1,471,774,581 | 439,823,205 | 1,792,279,560 |
| សមតុល្យនៅធនាគារផ្សេងៗ | 5 | 3,357,206 | 13,764,545 | 1,092,239 | 4,450,874 |
| ឥណទានផ្តល់ដល់អតិថិជន | 6 | 2,801,299,396 | 11,485,327,524 | 2,468,225,611 | 10,058,019,365 |
| ទ្រព្យសកម្មផ្សេងៗ | 7 | 3,154,340 | 12,932,794 | 8,723,049 | 35,546,425 |
| ទ្រព្យ និងបរិក្ខារ | 8 | 5,881,780 | 24,115,298 | 4,906,287 | 19,993,120 |
| សិទ្ធិក្នុងការប្រើប្រាស់ទ្រព្យសកម្ម | 9 | 15,763,364 | 64,629,792 | 14,360,265 | 58,518,080 |
| ទ្រព្យសកម្មអរូបី | 10 | 1,659,042 | 6,802,072 | 1,499,886 | 6,112,035 |
| ពន្ធពន្យារជាទ្រព្យសកម្ម | 17.3 | 13,551,645 | 55,561,745 | 9,198,173 | 37,482,555 |
| **ទ្រព្យសកម្មសរុប** | | **3,339,360,137** | **13,691,376,562** | **3,098,531,070** | **12,626,514,111** |
| **បំណុល និងមូលធនម្ចាស់ភាគហ៊ុន** | | | | | |
| **បំណុល** | | | | | |
| ប្រាក់បញ្ញើពីគ្រឹះស្ថានធនាគារ និងស្ថាប័នហិរញ្ញវត្ថុផ្សេងៗ | 11 | 53,226,556 | 218,228,880 | 55,092,001 | 224,499,904 |
| ប្រាក់បញ្ញើពីអតិថិជន | 12 | 1,956,229,175 | 8,020,539,618 | 1,733,440,925 | 7,063,771,769 |
| ប្រាក់កម្ចី | 13 | 658,114,268 | 2,698,268,499 | 724,296,717 | 2,951,509,122 |
| មូលបត្របំណុលត្រូវសង | 14 | 29,723,115 | 121,864,772 | - | - |
| អនុបំណុល | 15 | 64,799,225 | 265,676,823 | 75,910,811 | 309,336,555 |
| បំណុលភតិសន្យា | 16 | 14,787,012 | 60,626,749 | 13,172,728 | 53,678,867 |
| បំណុលពន្ធលើប្រាក់ចំណេញ | 17.2 | 17,292,738 | 70,900,226 | 23,414,889 | 95,415,673 |
| សំវិធានធនលើអត្ថប្រយោជន៍បុគ្គលិក | 18 | 1,383,837 | 5,673,732 | 74,562 | 303,840 |
| បំណុលផ្សេងៗ | 19 | 71,014,218 | 291,158,292 | 63,119,300 | 257,211,148 |
| **បំណុលសរុប** | | **2,866,570,144** | **11,752,937,591** | **2,688,521,933** | **10,955,726,878** |
| **មូលធនម្ចាស់ភាគហ៊ុន** | | | | | |
| ដើមទុន | 20 | 230,000,000 | 920,000,000 | 230,000,000 | 920,000,000 |
| ប្រាក់ចំណេញរក្សាទុក | | 239,652,696 | 978,433,688 | 172,806,881 | 705,569,074 |
| ទុនបម្រុង | 20 | 3,137,297 | 12,713,646 | 3,093,332 | 12,534,181 |
| ទុនបម្រុងបទប្បញ្ញត្តិ | 20 | - | - | 4,108,924 | 16,649,360 |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | 27,291,637 | - | 16,034,618 |
| **មូលធនម្ចាស់ភាគហ៊ុនសរុប** | | **472,789,993** | **1,938,438,971** | **410,009,137** | **1,670,787,233** |
| **បំណុល និងមូលធនម្ចាស់ភាគហ៊ុនសរុប** | | **3,339,360,137** | **13,691,376,562** | **3,098,531,070** | **12,626,514,111** |

*កំណត់សម្គាល់ដែលភ្ជាប់ជាមួយពីលេខ 1 ដល់ 32 ជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុសង្ខេបក្នុងគ្រាដែលមិនបានធ្វើសវនកម្ម។*

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក

*(ពីមុនជា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់)*

## របាយការណ៍លទ្ធផលពេញលេញសង្ខេបក្នុងគ្រាមិនបានធ្វើសវនកម្ម

សម្រាប់ការិយបរិច្ឆេទបញ្ចប់ 9ខែ នាថ្ងៃទី30 ខែកញ្ញា ឆ្នាំ2020

| | *កំណត់សម្គាល់* | *សម្រាប់ការិយបរិច្ឆេទបញ្ចប់ 9ខែ នាថ្ងៃទី30 ខែកញ្ញា ឆ្នាំ2020 (មិនបានធ្វើសវនកម្ម)* | | *សម្រាប់ការិយបរិច្ឆេទបញ្ចប់ 9ខែ នាថ្ងៃទី30 ខែកញ្ញា ឆ្នាំ2019 (មិនបានធ្វើសវនកម្ម)* | |
|---|---|---|---|---|---|
| | | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ 2.2)* | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ 2.2)* |
| ចំណូលពីការប្រាក់ | 21 | 314,804,576 | 1,285,188,694 | 274,188,089 | 1,110,403,378 |
| ចំណាយការប្រាក់ | 22 | (149,395,996) | (609,907,695) | (122,637,306) | (496,662,374) |
| **ចំណូលពីការប្រាក់សុទ្ធ** | | **165,408,580** | **675,280,999** | **151,550,783** | **613,741,004** |
| ចំណូលកម្រៃជើងសា | 23 | 4,555,329 | 18,607,145 | 1,917,497 | 7,810,274 |
| ចំណាយពីកម្រៃជើងសា | 23 | (142,070) | (580,593) | (106,969) | (432,613) |
| **ចំណូលសុទ្ធពីកម្រៃជើងសា** | | **4,413,259** | **18,026,552** | **1,810,528** | **7,377,661** |
| ចំណូលផ្សេងៗ | 24 | 6,752,655 | 27,564,682 | 9,475,742 | 38,320,736 |
| ចំណូលវិភាគទាន | | 589,545 | 2,409,284 | - | - |
| ចំណេញ(ខាត)សុទ្ធពីការប្តូររូបិយប័ណ្ណ | | 290,939 | 1,192,149 | (834,699) | (3,395,744) |
| **ចំណូលផ្សេងៗសរុប** | | **7,633,139** | **31,166,115** | **8,641,043** | **34,924,992** |
| **ចំណូលសរុបពីការប្រាក់ កម្រៃជើងសា និងចំណូលផ្សេងៗ** | | **177,454,978** | **724,473,666** | **162,002,354** | **656,043,657** |
| ចំណាយលើបុគ្គលិក | 25 | (52,441,424) | (214,088,401) | (45,340,533) | (183,581,835) |
| សំវិធានធនលើការខាតឥណទានរំពឹងទុក | 6 | (29,799,480) | (121,582,236) | (11,603,413) | (47,043,178) |
| ចំណាយទូទៅ និងរដ្ឋបាល | 26 | (11,803,888) | (48,187,501) | (9,217,074) | (37,315,962) |
| ចំណាយរំលស់ | 27 | (4,888,677) | (19,958,399) | (4,513,382) | (18,273,905) |
| **ប្រាក់ចំណេញមុនបង់ពន្ធ** | | **78,521,509** | **320,657,129** | **91,327,952** | **369,828,777** |
| ចំណាយពន្ធលើប្រាក់ចំណេញ | 17.1 | (15,740,653) | (64,279,625) | (18,308,532) | (74,138,849) |
| **ប្រាក់ចំណេញសុទ្ធក្នុងការិយបរិច្ឆេទ** | | **62,780,856** | **256,377,504** | **73,019,420** | **295,689,928** |
| *ធាតុនៃលទ្ធផលពេញលេញផ្សេងទៀត* | | | | | |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | 11,257,019 | - | 27,339,208 |
| **លទ្ធផលពេញលេញសរុប** | | **62,780,856** | **267,634,523** | **73,019,420** | **323,029,136** |

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក
*(ពីមុនជា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់)*

## របាយការណ៍លទ្ធផលពេញលេញសង្ខេបក្នុងគ្រាមិនបានធ្វើសវនកម្ម (តពីទំព័រមុន)
សម្រាប់ការិយបរិច្ឆេទបញ្ចប់ 3ខែ នាថ្ងៃទី30 ខែកញ្ញា ឆ្នាំ2020

| | កំណត់សម្គាល់ | *សម្រាប់ការិយបរិច្ឆេទបញ្ចប់ 3ខែ នាថ្ងៃទី30 ខែកញ្ញា ឆ្នាំ2020 (មិនបានធ្វើសវនកម្ម)* | | *សម្រាប់ការិយបរិច្ឆេទបញ្ចប់ 3ខែ នាថ្ងៃទី30 ខែកញ្ញា ឆ្នាំ2019 (មិនបានធ្វើសវនកម្ម)* | |
|---|---|---|---|---|---|
| | | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ 2.2)* | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ 2.2)* |
| ចំណូលពីការប្រាក់ | 21 | 107,644,290 | 440,803,368 | 98,268,400 | 401,622,951 |
| ចំណាយការប្រាក់ | 22 | (51,032,296) | (208,977,252) | (44,080,464) | (180,156,856) |
| **ចំណូលពីការប្រាក់សុទ្ធ** | | **56,611,994** | **231,826,116** | **54,187,936** | **221,466,095** |
| ចំណូលកម្រៃជើងសា | 23 | 2,085,496 | 8,540,106 | 1,459,979 | 5,966,934 |
| ចំណាយពីកម្រៃជើងសា | 23 | (79,784) | (326,715) | (28,181) | (115,176) |
| **ចំណូលសុទ្ធពីកម្រៃជើងសា** | | **2,005,712** | **8,213,391** | **1,431,798** | **5,851,758** |
| ចំណូលផ្សេងៗ | 24 | 2,150,525 | 8,806,400 | 2,465,031 | 10,074,582 |
| ចំណូលវិភាគទាន | | 331,529 | 1,357,611 | - | - |
| ចំណេញ(ខាត)សុទ្ធពីការប្តូររូបិយប័ណ្ណ | | 330,605 | 1,353,827 | (564,501) | (2,307,116) |
| **ចំណូលផ្សេងៗសរុប** | | **2,812,659** | **11,517,838** | **1,900,530** | **7,767,466** |
| **ចំណូលសរុបពីការប្រាក់ កម្រៃជើងសានិងចំណូលផ្សេងៗ** | | **61,430,365** | **251,557,345** | **57,520,264** | **235,085,319** |
| ចំណាយលើបុគ្គលិក | 25 | (17,745,080) | (72,666,103) | (15,600,474) | (63,759,137) |
| សំវិធានធនលើការខាតឥណទានរំពឹងទុក | 6 | (6,292,408) | (25,767,411) | (5,052,183) | (20,648,272) |
| ចំណាយទូទៅ និងរដ្ឋបាល | 26 | (3,939,557) | (16,132,486) | (3,109,835) | (12,709,896) |
| ចំណាយរំលស់ | 27 | (1,692,253) | (6,929,776) | (1,542,923) | (6,305,926) |
| **ប្រាក់ចំណេញមុនបង់ពន្ធ** | | **31,761,067** | **130,061,569** | **32,214,849** | **131,662,088** |
| ចំណាយពន្ធលើប្រាក់ចំណេញ | 17.1 | (6,353,724) | (26,018,500) | (6,444,385) | (26,338,201) |
| **ប្រាក់ចំណេញសុទ្ធក្នុងការិយបរិច្ឆេទ** | | **25,407,343** | **104,043,069** | **25,770,464** | **105,323,887** |
| *ធាតុនៃលទ្ធផលពេញលេញផ្សេងទៀត* | | | | | |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | 3,340,119 | - | 10,878,811 |
| **លទ្ធផលពេញលេញសរុប** | | **25,407,343** | **107,383,188** | **25,770,464** | **116,202,698** |

*កំណត់សម្គាល់ដែលភ្ជាប់ជាមួយពីលេខ 1 ដល់ 32 ជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុសង្ខេបក្នុងគ្រាដែលមិនបានធ្វើសវនកម្ម។*

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក

*(ពីមុនជា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់)*

## របាយការណ៍បម្រែបម្រួលមូលធនសង្ខេបក្នុងគ្រាមិនបានធ្វើសវនកម្ម

សម្រាប់ការិយបរិច្ឆេទបញ្ចប់ 9ខែ នាថ្ងៃទី30 ខែកញ្ញា ឆ្នាំ2020

| | *ដើមទុន* | *ប្រាក់ចំណេញរក្សាទុក* | *ទុនបម្រុង* | *ទុនបម្រុងបទប្បញ្ញត្តិ* | *លម្អៀងបង្គរពីការប្តូររូបិយប័ណ្ណ* | *សរុប* |
|---|---|---|---|---|---|---|
| | *ដុល្លារអាមេរិក* | *ដុល្លារអាមេរិក* | *ដុល្លារអាមេរិក* | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល* | *ដុល្លារអាមេរិក* |
| សមតុល្យនាថ្ងៃទី1 ខែមករា ឆ្នាំ2020 | 230,000,000 | 172,806,881 | 3,093,332 | 4,108,924 | 16,034,618 | 410,009,137 |
| ប្រាក់ចំណេញក្នុងការិយបរិច្ឆេទ | - | 62,780,856 | - | - | - | 62,780,856 |
| ផ្ទេរពីទុនបម្រុងបទប្បញ្ញត្តិ | - | 4,108,924 | - | (4,108,924) | - | - |
| ផ្ទេរទៅទុនបម្រុង | - | (43,965) | 43,965 | - | - | - |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | 11,257,019 | - |
| **សមតុល្យនាថ្ងៃទី30 ខែកញ្ញា ឆ្នាំ2020** | **230,000,000** | **239,652,696** | **3,137,297** | **-** | **-** | **472,789,993** |
| **សមមូលពាន់រៀល** *(កំណត់សម្គាល់ 2.2)* | **920,000,000** | **978,433,688** | **12,713,646** | **-** | **27,291,637** | **1,938,438,971** |
| សមតុល្យនាថ្ងៃទី1 ខែមករា ឆ្នាំ2019 | 110,000,000 | 193,228,719 | 2,976,091 | 299,009 | (3,793,798) | 306,503,819 |
| ប្រាក់ចំណេញក្នុងការិយបរិច្ឆេទ | - | 73,019,420 | - | - | - | 73,019,420 |
| ផ្ទេរប្រាក់ចំណេញរក្សាទុកទៅជាដើមទុន | 58,000,000 | (58,000,000) | - | - | - | - |
| ផ្ទេរទៅទុនបម្រុងបទប្បញ្ញត្តិ | - | (918,293) | - | 918,293 | - | - |
| ផ្ទេរទៅទុនបម្រុង | - | (87,930) | 87,930 | - | - | - |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | 27,339,208 | - |
| **សមតុល្យនាថ្ងៃទី30 ខែកញ្ញា ឆ្នាំ2019** | **168,000,000** | **207,241,916** | **3,064,021** | **1,217,302** | **-** | **379,523,239** |
| **សមមូលពាន់រៀល** *(កំណត់សម្គាល់ 2.2)* | **672,000,000** | **841,659,798** | **12,394,317** | **4,927,658** | **23,545,410** | **1,554,527,183** |

*កំណត់សម្គាល់ដែលភ្ជាប់ជាមួយពីលេខ 1 ដល់ 32 ជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុសង្ខេបក្នុងគ្រាដែលមិនបានធ្វើសវនកម្ម។*

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក
*(ពីមុនជា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់)*

## របាយការណ៍លំហូរសាច់ប្រាក់សង្ខេបក្នុងគ្រាមិនបានធ្វើសវនកម្ម
សម្រាប់ការិយបរិច្ឆេទបញ្ចប់ ៩ខែ នាថ្ងៃទី30 ខែកញ្ញា ឆ្នាំ2020

| | *កំណត់សម្គាល់* | *សម្រាប់ការិយបរិច្ឆេទបញ្ចប់ ៩ខែ នាថ្ងៃទី30 ខែកញ្ញា ឆ្នាំ2020 (មិនបានធ្វើសវនកម្ម)* | | *សម្រាប់ការិយបរិច្ឆេទបញ្ចប់ ៩ខែ នាថ្ងៃទី30 ខែកញ្ញា ឆ្នាំ2019 (មិនបានធ្វើសវនកម្ម)* | |
|---|---|---|---|---|---|
| | | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ 2.2)* | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ 2.2)* |
| **សកម្មភាពប្រតិបត្តិការ** | | | | | |
| **សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុងសកម្មភាពប្រតិបត្តិការ** | 28 | **(61,382,137)** | **(268,218,163)** | **(80,161,515)** | **(379,714,633)** |
| **សកម្មភាពវិនិយោគ** | | | | | |
| *ការទិញ:* | | | | | |
| ទ្រព្យ និងបរិក្ខារ | 8 | (2,585,827) | (10,549,859) | (1,426,128) | (5,841,420) |
| ទ្រព្យសកម្មអរូបី | 10 | (436,007) | (1,777,564) | (232,385) | (951,849) |
| ការវិនិយោគលើមូលបត្រអាចជួញដូរបាន | | 147,561 | 605,000 | - | - |
| សាច់ប្រាក់ពីការលក់ទ្រព្យនិងបរិក្ខារ | | 10,872 | 44,576 | 18,729 | 76,712 |
| **សាច់ប្រាក់សុទ្ធប្រើក្នុងសកម្មភាពវិនិយោគ** | | **(2,863,401)** | **(11,677,847)** | **(1,639,784)** | **(6,716,557)** |
| **សកម្មភាពហិរញ្ញប្បទាន** | | | | | |
| *សាច់ប្រាក់បានពី:* | | | | | |
| កម្ចី | | 254,086,688 | 1,042,378,952 | 195,185,786 | 799,480,979 |
| មូលបត្របំណុលត្រូវសង | | 31,176,471 | 127,200,000 | - | - |
| *ការទូទាត់នៃ:* | | | | | |
| ប្រាក់កម្ចី | | (319,541,830) | (1,310,121,504) | (147,798,241) | (605,381,595) |
| អនុបំណុល | | (9,489,625) | (38,907,463) | (10,833,333) | (44,373,332) |
| បំណុលភតិសន្យា | | (2,776,880) | (11,385,208) | (3,078,364) | (12,608,979) |
| **សាច់ប្រាក់សុទ្ធបានមកពីសកម្មភាពហិរញ្ញប្បទាន** | | **(46,545,176)** | **(190,835,223)** | **33,475,848** | **137,117,073** |
| **ការថយចុះសុទ្ធនៃសាច់ប្រាក់ និងសាច់ប្រាក់សមមូល** | | **(110,790,714)** | **(470,731,233)** | **(48,325,451)** | **(249,314,117)** |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូលនៅដើមគ្រា | | 430,311,373 | 1,753,518,845 | 291,145,194 | 1,169,821,389 |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | (4,004,844) | 10,827,229 | 1,955,705 | 82,092,962 |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលនាចុងការិយបរិច្ឆេទ** | 3 | **315,515,815** | **1,293,614,841** | **244,775,448** | **1,002,600,234** |
| **ប្រតិបត្តិការ លំហូរសាច់ប្រាក់ពីការប្រាក់** | | | | | |
| ការប្រាក់បានទទួល | | 311,960,203 | 1,273,018,523 | 269,866,667 | 1,104,044,082 |
| ការប្រាក់បានបង់ | | 148,960,212 | 606,676,782 | 114,255,898 | 464,763,655 |

*កំណត់សម្គាល់ដែលភ្ជាប់ជាមួយពីលេខ 1 ដល់ 32 ជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុសង្ខេបក្នុងគ្រាដែលមិនបានធ្វើសវនកម្ម។*

## គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក
*(ពីមុនជា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់)*

**កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបក្នុងគ្រាមិនបានធ្វើសវនកម្ម**
នាថ្ងៃទី30 ខែកញ្ញា ឆ្នាំ2020 និងសម្រាប់ការិយបរិច្ឆេទបញ្ចប់ 9ខែ

### 1. ព័ត៌មានអំពីសាជីវកម្ម

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់ ម.ក ហៅកាត់ថា ("ក្រុមហ៊ុន") គឺជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលទទួលបានអាជ្ញាប័ណ្ណ និងចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

*ការបង្កើតនិងប្រតិបត្តិការ*

ក្រុមហ៊ុន ត្រូវបានបង្កើតឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយបានចុះបញ្ជីជាមួយក្រសួងពាណិជ្ជកម្ម ជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ក្រោមបញ្ជីពាណិជ្ជកម្មលេខ 00001157 នាថ្ងៃទី19 ខែកញ្ញា ឆ្នាំ2011 ដែលបានចុះបញ្ជីសារជាថ្មី នាថ្ងៃទី28 ខែមេសា ឆ្នាំ2016។

ធនាគារជាតិនៃកម្ពុជា បានផ្តល់អាជ្ញាប័ណ្ណមីក្រូហិរញ្ញវត្ថុឲ្យក្រុមហ៊ុន ដែលមានសុពលភាពចាប់ពីថ្ងៃទី14 ខែធ្នូ ឆ្នាំ2007។ លើសពីនេះទៅទៀតក្រុមហ៊ុនបានទទួលអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា ដើម្បីធ្វើអាជីវកម្មទទួលប្រាក់បញ្ញើ នៅថ្ងៃទី27 ខែសីហា ឆ្នាំ2010 និង ការអនុញ្ញាតឲ្យដំណើរការម៉ាស៊ីនដក-ដាក់ប្រាក់ស្វ័យប្រវត្តិ និងសេវាកម្មបង់ប្រាក់តាមម៉ាស៊ីនឆូតកាត នៅថ្ងៃទី01 ខែធ្នូ ឆ្នាំ2011។

សកម្មភាពចម្បងរបស់ក្រុមហ៊ុន គឺផ្តល់សេវាកម្មហិរញ្ញវត្ថុដល់សហគមន៍ជនបទនិងសហគ្រាសខ្នាតតូចក្នុងប្រទេសកម្ពុជា តាមរយៈការិយាល័យកណ្តាលរបស់ក្រុមហ៊ុន នៅក្នុងរាជធានីភ្នំពេញ និងសាខាជាច្រើននៅក្នុងរាជធានីភ្នំពេញ និងខេត្តនានាក្នុងប្រទេសកម្ពុជា។

ស្នាក់ការចុះបញ្ជីរបស់ក្រុមហ៊ុន មានទីតាំងស្ថិតនៅអគារលេខ 212 ផ្លូវលេខ 271 សង្កាត់ទូលទំពូង2 ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

*អំពីបុគ្គលិក*

នាថ្ងៃទី30 ខែកញ្ញា ឆ្នាំ2020 ក្រុមហ៊ុនមានបុគ្គលិកចំនួន 9,161 នាក់ (ថ្ងៃទី31 ខែធ្នូ ឆ្នាំ2019 មានបុគ្គលិកចំនួន 9,091 នាក់)។

*ការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ*

របាយការណ៍ហិរញ្ញវត្ថុសង្ខេបក្នុងគ្រាដែលមិនបានធ្វើសវនកម្ម ត្រូវបានអនុម័តដោយក្រុមប្រឹក្សាភិបាលនៅថ្ងៃទី12 ខែវិច្ឆិកា ឆ្នាំ2020។

### 2. គោលនយោបាយគណនេយ្យសំខាន់

#### *2.1 ការប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុសង្ខេបក្នុងគ្រា និង មូលដ្ឋាននៃការរៀបចំ*

របាយការណ៍ហិរញ្ញវត្ថុសង្ខេបក្នុងគ្រា ដែលមិនបានធ្វើសវនកម្មត្រូវបានរៀបចំឡើងដោយផ្អែកលើមូលដ្ឋានថ្លៃដើមប្រវត្តិសាស្ត្រ។ ក្រុមហ៊ុនរក្សាកំណត់ត្រានិងរៀបចំរបាយការណ៍ហិរញ្ញវត្ថុជាប្រាក់រៀល ("KHR") ប្រាក់បាតថៃ ("THB") និងដុល្លារអាមេរិក ("USD")។ ថ្នាក់គ្រប់គ្រងបានកំណត់ប្រាក់ដុល្លារជារូបិយប័ណ្ណសម្រាប់ធ្វើការវាស់វែង និងការបង្ហាញរបស់ក្រុមហ៊ុន ព្រោះវាឆ្លុះបញ្ចាំងពីសារធាតុសេដ្ឋកិច្ចនៃមូលដ្ឋានព្រឹត្តិការណ៍កាលៈទេសៈរបស់ក្រុមហ៊ុន។

## 2. **គោលនយោបាយគណនេយ្យសំខាន់** (តពីទំព័រមុន)

### *2.1 ការប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុសង្ខេបក្នុងគ្រា និង មូលដ្ឋាននៃការរៀបចំ* (តពីទំព័រមុន)

របាយការណ៍ហិរញ្ញវត្ថុសង្ខេបក្នុងគ្រាដែលមិនបានធ្វើសវនកម្ម នាថ្ងៃទី30 ខែកញ្ញា ឆ្នាំ2020 និងសម្រាប់ការិយបរិច្ឆេទបញ្ចប់ 9ខែ ត្រូវបានរៀបចំដោយអនុលោមតាមស្តង់ដារគណនេយ្យអន្តរជាតិនៃកម្ពុជាលេខ 34 *ការរាយការណ៍ហិរញ្ញវត្ថុក្នុងគ្រា*។ ដូច្នោះហើយ របាយការណ៍ហិរញ្ញវត្ថុសង្ខេបក្នុងគ្រាដែលមិនបានធ្វើសវនកម្មនេះ មិនរាប់បញ្ចូលរាល់ព័ត៌មាននិងការលាតត្រដាងដែលត្រូវការដូចនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំទេ ហើយត្រូវអានរួមជាមួយរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំរបស់ក្រុមហ៊ុន នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2019 និងសម្រាប់ការិយបរិច្ឆេទបញ្ចប់ ដែលត្រូវបានរៀបចំស្របតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា។

គោលនយោបាយគណនេយ្យដែលបានអនុម័តក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុសង្ខេបក្នុងគ្រាដែលមិនបានធ្វើសវនកម្ម មានភាពស៊ីគ្នាទៅនឹងគោលការណ៍ដែលបានអនុវត្តនៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មនៅថ្ងៃទី31 ខែធ្នូ ឆ្នាំ2019 និងសម្រាប់ការិយបរិច្ឆេទបញ្ចប់។

ប្រតិបត្តិការតាមរដូវកាល ក្នុងគ្រាមិនត្រូវបានអនុវត្តចំពោះប្រភេទអាជីវកម្មរបស់ក្រុមហ៊ុនឡើយ។

### *2.2 ការប្រែសម្រួលរូបិយប័ណ្ណប្រាក់ដុល្លារអាមេរិកទៅប្រាក់រៀល*

ទ្រព្យសកម្ម និងបំណុលត្រូវបានប្រែសម្រួលដោយប្រើអត្រាប្តូរប្រាក់ចុងគ្រា នាការិយបរិច្ឆេទនៃរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ និងដើមទុនត្រូវបានប្រែសម្រួលតាមអត្រាពីមុន 4,000 រៀល ក្នុង 1 ដុល្លារអាមេរិក។ ភាពលម្អៀងពីការប្តូររូបិយប័ណ្ណដែលកើតឡើង ពីការប្រែសម្រួលត្រូវបានទទួលស្គាល់ និងបង្គរនៅក្នុងលម្អៀងពីការប្តូររូបិយប័ណ្ណដែលបានបង្ហាញនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។

របាយការណ៍ហិរញ្ញវត្ថុត្រូវបានបង្ហាញជាប្រាក់រៀល ដោយផ្អែកលើអត្រាប្តូរប្រាក់អនុវត្តដូចខាងក្រោមក្នុង 1 ដុល្លារអាមេរិក៖

| | *ថ្ងៃទី30 ខែកញ្ញា ឆ្នាំ2020* | *ថ្ងៃទី31 ខែធ្នូ ឆ្នាំ2019* | *ថ្ងៃទី30 ខែកញ្ញា ឆ្នាំ2019* |
|---|---|---|---|
| អត្រាចុងគ្រា | 4,100 | 4,075 | 4,096 |
| អត្រាមធ្យម3ខែ | 4,095 | N/A | 4,087 |

## 3. សាច់ប្រាក់ក្នុងដៃ

| | *ថ្ងៃទី30 ខែកញ្ញា ឆ្នាំ2020 (មិនបានធ្វើសវនកម្ម)* | | *ថ្ងៃទី31 ខែធ្នូ ឆ្នាំ2019 (បានធ្វើសវនកម្ម)* | |
|---|---|---|---|---|
| | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ 2.2)* | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ 2.2)* |
| ទីស្នាក់ការកណ្តាល | 39,946,107 | 163,779,039 | 25,521,565 | 104,000,377 |
| សាខានានា | 95,777,847 | 392,689,172 | 125,180,790 | 510,111,720 |
| | **135,723,954** | **556,468,211** | **150,702,355** | **614,112,097** |

សម្រាប់គោលបំណងនៃការរៀបចំរបាយការណ៍លំហូរសាច់ប្រាក់ សាច់ប្រាក់ និងសាច់ប្រាក់សមមូលរួមមានដូចខាងក្រោម៖

| | *សម្រាប់ការិយបរិច្ឆេទបញ្ចប់ 9ខែ នាថ្ងៃទី30 ខែកញ្ញា ឆ្នាំ2020 (មិនបានធ្វើសវនកម្ម)* | | *សម្រាប់ការិយបរិច្ឆេទបញ្ចប់ 9ខែ នាថ្ងៃទី30 ខែកញ្ញា ឆ្នាំ2019 (មិនបានធ្វើសវនកម្ម)* | |
|---|---|---|---|---|
| | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ 2.2)* | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ 2.2)* |
| សាច់ប្រាក់ក្នុងដៃ | 135,723,954 | 556,468,211 | 97,681,807 | 400,104,681 |
| *សមតុល្យនៅធនាគារជាតិនៃកម្ពុជា* | | | | |
| គណនីចរន្ត | 126,177,573 | 517,328,049 | 42,927,554 | 175,831,261 |
| គណនីមានកាលកំណត់ (រហូតដល់3ខែ) | 50,223,171 | 205,915,001 | 100,295,898 | 410,811,998 |
| *សមតុល្យនៅធនាគារផ្សេងៗ* | | | | |
| គណនីចរន្ត | 3,161,014 | 12,960,158 | 3,726,847 | 15,265,165 |
| គណនីសន្សំ | 230,103 | 943,422 | 143,342 | 587,129 |
| | **315,515,815** | **1,293,614,841** | **244,775,448** | **1,002,600,234** |

## 4. សមតុល្យនៅធនាគារជាតិនៃកម្ពុជា

| | *ថ្ងៃទី30 ខែកញ្ញា ឆ្នាំ2020 (មិនបានធ្វើសវនកម្ម)* | | *ថ្ងៃទី31 ខែធ្នូ ឆ្នាំ2019 (បានធ្វើសវនកម្ម)* | |
|---|---|---|---|---|
| | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ 2.2)* | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ 2.2)* |
| គណនីចរន្ត | 126,177,573 | 517,328,049 | 148,644,233 | 605,725,249 |
| ប្រាក់បញ្ញើមានកាលកំណត់ (រហូតដល់3ខែ) | 50,223,171 | 205,915,001 | 129,872,546 | 529,230,625 |
| ប្រាក់បញ្ញើមានកាលកំណត់ (ច្រើនជាង3ខែ) | 147,561 | 605,000 | 148,160 | 603,752 |
| ប្រាក់តម្កល់ធានាលើដើមទុន | 23,000,000 | 94,300,000 | 23,000,000 | 93,725,000 |
| ប្រាក់បម្រុងកាតព្វកិច្ច | 159,421,105 | 653,626,531 | 138,158,266 | 562,994,934 |
| | **358,969,410** | **1,471,774,581** | **439,823,205** | **1,792,279,560** |

គណនីចរន្តមិនទទួលបានការប្រាក់នោះទេ។

ប្រាក់បញ្ញើមានកាលកំណត់រហូតដល់ 3ខែ ត្រូវទទួលបានការប្រាក់ប្រចាំឆ្នាំចាប់ពី 0.03% ដល់ 1.55% (2019៖ ចាប់ពី 0.11% ដល់ 0.76%) ហើយលើសពី 3ខែ នឹងទទួលបានអត្រាប្រចាំឆ្នាំចាប់ពី 0.23% ដល់1.93% (2019៖ ចាប់ពី 0.30% ដល់ 2.75%)។

តាមប្រកាសលេខ B7-07-163 ចុះថ្ងៃទី13 ខែធ្នូ ឆ្នាំ2007 ស្តីអំពីការផ្តល់អាជ្ញាប័ណ្ណដល់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ក្រុមហ៊ុនតម្រូវឲ្យរក្សាប្រាក់តម្កល់ធានាលើដើមទុនស្មើនឹង 10% នៃដើមទុនចុះបញ្ជីជាមួយធនាគារជាតិនៃកម្ពុជា។ ប្រាក់បញ្ញើនេះមិនអាចយកសម្រាប់ការប្រើប្រាស់នៅក្នុងប្រតិបត្តិការរបស់ក្រុមហ៊ុននោះទេ ប៉ុន្តែត្រូវបានបង្វិលសងវិញនៅពេលក្រុមហ៊ុនស្ម័គ្រចិត្តបញ្ឈប់អាជីវកម្មនៅក្នុងប្រទេសកម្ពុជា។ ប្រាក់តម្កល់ធានាលើដើមទុនទទួលបាន ការប្រាក់ប្រចាំឆ្នាំចំនួន 0.09% នៅក្នុងការិយបរិច្ឆេទ (2019៖ 3.00%)។ ចំណូលពីការប្រាក់ ដែលទទួលបានពីសមតុល្យនៅធនាគារជាតិនៃកម្ពុជា មានចំនួន 136,471 ដុល្លារអាមេរិក និង 456,755 ដុល្លារអាមេរិក នាថ្ងៃទី30 ខែកញ្ញា ឆ្នាំ2020 និង ឆ្នាំ2019 រៀងគ្នា *(កំណត់សម្គាល់លេខ 15)*។

ប្រាក់បម្រុងកាតព្វកិច្ច គឺជាប្រាក់បម្រុងកាតព្វកិច្ចអប្បបរមា ដែលត្រូវបានគណនាតាមអត្រា 8% នៃប្រាក់បញ្ញើរបស់អតិថិជន ដោយអនុលោមទៅតាមប្រកាសរបស់ធនាគារជាតិនៃកម្ពុជាលេខ B7-07-163។ ប្រាក់បម្រុងកាតព្វកិច្ច តម្រូវឲ្យមានការបត់បែនដោយផ្អែកលើកម្រិតនៃការដាក់ប្រាក់បញ្ញើពីអតិថិជន ហើយប្រាក់បម្រុងកាតព្វកិច្ច ពុំទទួលបានការប្រាក់នោះទេ។

## 5. សមតុល្យនៅធនាគារផ្សេងៗ

| | ថ្ងៃទី30 ខែកញ្ញា ឆ្នាំ2020 (មិនបានធ្វើសវនកម្ម) | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2019 (បានធ្វើសវនកម្ម) | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ 2.2) | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ 2.2) |
| គណនីចរន្ត | 3,161,014 | 12,960,158 | 1,060,912 | 4,323,216 |
| គណនីសន្សំ | 230,103 | 943,422 | 42,360 | 172,617 |
| សមតុល្យដុលជាមួយធនាគារផ្សេងៗ | 3,391,117 | 13,903,580 | 1,103,272 | 4,495,833 |
| សំវិធានធនលើ ECLs | (33,911) | (139,035) | (11,033) | (44,959) |
| **សុទ្ធ** | **3,357,206** | **13,764,545** | **1,092,239** | **4,450,874** |

គណនីចរន្ត ទទួលបានការប្រាក់ចាប់ពីចាប់ពី 0.25% ដល់ 1.00%។ គណនីសន្សំទទួលបានអត្រាការប្រាក់ប្រចាំឆ្នាំចាប់ពី 0.15% ទៅ 1.00% ក្នុងការិយបរិច្ឆេទ (2019៖ 0.00% ទៅ 0.75%)។

## 6. ឥណទានផ្តល់ដល់អតិថិជន

ឥណទានផ្តល់ដល់អតិថិជនដែលត្រូវបានចាត់ថ្នាក់ដូចខាងក្រោម៖

| | ថ្ងៃទី30 ខែកញ្ញា ឆ្នាំ2020 (មិនបានធ្វើសវនកម្ម) | | | | |
|---|---|---|---|---|---|
| | ដំណាក់កាលទី 1 | ដំណាក់កាលទី 2 | ដំណាក់កាលទី 3 | សរុប | |
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ 2.2) |
| ឥណទានបុគ្គល | 2,721,754,291 | 54,455,816 | 31,748,334 | 2,807,958,441 | 11,512,629,608 |
| ឥណទានសម្រាប់សហគ្រាសធុនតូចនិងមធ្យម | 42,648,875 | 2,242,362 | 1,409,241 | 46,300,478 | 189,831,960 |
| ឥណទានបុគ្គលិក | 7,473,299 | 4,234 | 19,569 | 7,497,102 | 30,738,118 |
| ឥណទានក្រុម | 433,479 | 9,374 | 7,604 | 450,457 | 1,846,874 |
| | **2,772,309,944** | **56,711,786** | **33,184,748** | **2,862,206,478** | **11,735,046,560** |
| កម្រៃពីឥណទានដែលមិនទាន់ទទួលស្គាល់ | (27,264,658) | (518,181) | (291,158) | (28,073,997) | (115,103,388) |
| | **2,745,045,286** | **56,193,605** | **32,893,590** | **2,834,132,481** | **11,619,943,172** |
| ការប្រាក់បង្គរត្រូវទទួល | 20,203,518 | 692,617 | 2,277,971 | 23,174,106 | 95,013,835 |
| | **2,765,248,804** | **56,886,222** | **35,171,561** | **2,857,306,587** | **11,714,957,007** |
| សំវិធានធនលើ ECLs | (14,425,437) | (17,392,049) | (24,189,705) | (56,007,191) | (229,629,483) |
| **សុទ្ធ** | **2,750,823,367** | **39,494,173** | **10,981,856** | **2,801,299,396** | **11,485,327,524** |

## 6. **ឥណទានផ្តល់ដល់អតិថិជន** (តពីទំព័រមុន)

ឥណទានផ្តល់ដល់អតិថិជនដែលត្រូវបានចាត់ថ្នាក់ដូចខាងក្រោម៖ (តពីទំព័រមុន)

| | *ថ្ងៃទី31 ខែធ្នូ ឆ្នាំ 2019 (បានធ្វើសវនកម្ម)* | | | | |
|---|---|---|---|---|---|
| | *ដំណាក់កាលទី 1* | *ដំណាក់កាលទី 2* | *ដំណាក់កាលទី 3* | *សរុប* | |
| | *ដុល្លារអាមេរិក* | *ដុល្លារអាមេរិក* | *ដុល្លារអាមេរិក* | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ 2.2)* |
| ឥណទានបុគ្គល | 2,444,568,381 | 1,361,458 | 7,617,856 | 2,453,547,695 | 9,998,206,859 |
| ឥណទានសម្រាប់សហគ្រាសធុនតូចនិងមធ្យម | 38,119,736 | 16,211 | 199,753 | 38,335,700 | 156,217,977 |
| ឥណទានបុគ្គលិក | 8,766,819 | 192 | 1,377 | 8,768,388 | 35,731,180 |
| ឥណទានក្រុម | 642,973 | 885 | 627 | 644,485 | 2,626,275 |
| | **2,492,097,909** | **1,378,746** | **7,819,613** | **2,501,296,268** | **10,192,782,291** |
| កម្រៃពីឥណទានដែលមិនទាន់ទទួលស្គាល់ | (27,090,829) | (13,296) | (63,372) | (27,167,497) | (110,707,550) |
| | **2,465,007,080** | **1,365,450** | **7,756,241** | **2,474,128,771** | **10,082,074,741** |
| ការប្រាក់បង្គរត្រូវទទួល | 19,669,265 | 28,753 | 631,714 | 20,329,732 | 82,843,658 |
| | **2,484,676,345** | **1,394,203** | **8,387,955** | **2,494,458,503** | **10,164,918,399** |
| សំវិធានធនលើ ECLs | (18,696,858) | (481,191) | (7,054,843) | (26,232,892) | (106,899,034) |
| **សុទ្ធ** | **2,465,979,487** | **913,012** | **1,333,112** | **2,468,225,611** | **10,058,019,365** |

បម្រែបម្រួលសំវិធានធនលើ ECLs ត្រូវបានបង្ហាញដូចខាងក្រោម៖

| | *ថ្ងៃទី30 ខែកញ្ញា ឆ្នាំ2020 (មិនបានធ្វើសវនកម្ម)* | | *ថ្ងៃទី31 ខែធ្នូ ឆ្នាំ2019 (បានធ្វើសវនកម្ម)* | |
|---|---|---|---|---|
| | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ 2.2)* | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ 2.2)* |
| សមតុល្យដើមគ្រា | 26,232,892 | 106,899,034 | 26,663,309 | 107,133,176 |
| សំវិធានធនក្នុងឆ្នាំ | 29,774,299 | 121,479,369 | 9,359,990 | 37,926,679 |
| បំណុលលុបចេញពីបញ្ជីក្នុងឆ្នាំ | - | - | (9,790,407) | (39,670,729) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | 1,251,080 | - | 1,509,908 |
| **សមតុល្យចុងគ្រា/ឆ្នាំ** | **56,007,191** | **229,629,483** | **26,232,892** | **106,899,034** |

## 6. ឥណទានផ្តល់ដល់អតិថិជន (តពីទំព័រមុន)

ការវិភាគបន្ថែមនៃឥណទានដល់អតិថិជនត្រូវបានកំណត់ដូចខាងក្រោម៖

(ក) តាមទ្រព្យធានា

| | *ថ្ងៃទី30 ខែកញ្ញា ឆ្នាំ2020 (មិនបានធ្វើសវនកម្ម)* | | *ថ្ងៃទី31 ខែធ្នូ ឆ្នាំ2019 (បានធ្វើសវនកម្ម)* | |
|---|---|---|---|---|
| | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ 2.2)* | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ 2.2)* |
| មានវត្ថុបញ្ចាំ | | | | |
| អចលនទ្រព្យ | 165,242,679 | 677,494,984 | 167,125,162 | 681,035,035 |
| ចលនវត្ថុ | 121,239,601 | 497,082,364 | 90,812,685 | 370,061,691 |
| តម្កល់ប្រាក់ទុក | 767,425 | 3,146,443 | 719,708 | 2,932,810 |
| ផ្សេងៗ | 887,770,875 | 3,639,860,588 | 728,089,217 | 2,966,963,559 |
| ពុំមានវត្ថុបញ្ចាំ | | | | |
| អចលនទ្រព្យ | 229,474,210 | 940,844,261 | 240,791,888 | 981,226,944 |
| ចលនវត្ថុ | 158,085,659 | 648,151,202 | 133,443,891 | 543,783,856 |
| ផ្សេងៗ | 1,294,726,138 | 5,308,377,165 | 1,133,475,952 | 4,618,914,504 |
| សរុប | **2,857,306,587** | **11,714,957,007** | **2,494,458,503** | **10,164,918,399** |

(ខ) តាមកាលកំណត់

| | *ថ្ងៃទី30 ខែកញ្ញា ឆ្នាំ2020 (មិនបានធ្វើសវនកម្ម)* | | *ថ្ងៃទី31 ខែធ្នូ ឆ្នាំ2019 (បានធ្វើសវនកម្ម)* | |
|---|---|---|---|---|
| | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ 2.2)* | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់2.2)* |
| ក្នុងរយៈពេល 1ខែ | 81,803,228 | 335,393,235 | 82,075,603 | 334,458,081 |
| ច្រើនជាង 1ខែ ដល់ 3ខែ | 110,900,356 | 454,691,460 | 122,796,948 | 500,397,563 |
| ច្រើនជាង 3ខែ ដល់ 12ខែ | 545,739,599 | 2,237,532,356 | 498,491,384 | 2,031,352,390 |
| ច្រើនជាង 1ឆ្នាំ ដល់ 5ឆ្នាំ | 1,869,844,484 | 7,666,362,384 | 1,648,272,399 | 6,716,710,026 |
| ច្រើនជាង 5ឆ្នាំ | 249,018,920 | 1,020,977,572 | 142,822,169 | 582,000,339 |
| | **2,857,306,587** | **11,714,957,007** | **2,494,458,503** | **10,164,918,399** |

## 6. ឥណទានផ្តល់ដល់អតិថិជន (តពីទំព័រមុន)

ការវិភាគបន្ថែមនៃឥណទានដល់អតិថិជនត្រូវបានកំណត់ដូចខាងក្រោម៖ (តពីទំព័រមុន)

(គ) តាមនិវាសនភាព ទំនាក់ទំនង រូបិយប័ណ្ណ និងវិស័យឧស្សាហកម្ម

| | *ថ្ងៃទី30 ខែកញ្ញា ឆ្នាំ2020 (មិនបានធ្វើសវនកម្ម)* | | *ថ្ងៃទី31 ខែធ្នូ ឆ្នាំ2019 (បានធ្វើសវនកម្ម)* | |
|---|---|---|---|---|
| | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ 2.2)* | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ 2.2)* |
| *និវាសនភាព* | | | | |
| **និវាសនជន** | **2,857,306,587** | **11,714,957,007** | **2,494,458,503** | **10,164,918,399** |
| *ទំនាក់ទំនង* | | | | |
| អតិថិជនខាងក្រៅ | 2,849,822,703 | 11,684,273,082 | 2,485,691,351 | 10,129,192,255 |
| ឥណទានបុគ្គលិក | 7,483,884 | 30,683,925 | 8,767,152 | 35,726,144 |
| | **2,857,306,587** | **11,714,957,007** | **2,494,458,503** | **10,164,918,399** |
| *រូបិយប័ណ្ណ* | | | | |
| ដុល្លារអាមេរិក | 2,484,562,642 | 10,186,706,832 | 2,139,255,629 | 8,717,466,685 |
| ខ្មែររៀល | 344,792,120 | 1,413,647,692 | 305,131,677 | 1,243,411,587 |
| បាតថៃ | 27,951,825 | 114,602,483 | 50,071,197 | 204,040,127 |
| | **2,857,306,587** | **11,714,957,007** | **2,494,458,503** | **10,164,918,399** |
| *វិស័យឧស្សាហកម្ម* | | | | |
| ពាណិជ្ជកម្ម និងជំនួញ | 682,419,653 | 2,797,920,577 | 529,088,592 | 2,156,036,012 |
| សេវាកម្ម | 479,149,940 | 1,964,514,754 | 393,814,829 | 1,604,795,428 |
| កសិកម្ម | 405,924,023 | 1,664,288,494 | 437,528,199 | 1,782,927,411 |
| អចលនទ្រព្យ | 394,716,889 | 1,618,339,245 | 407,917,050 | 1,662,261,979 |
| កែលម្អគេហដ្ឋាន | 320,276,378 | 1,313,133,150 | 258,272,787 | 1,052,461,607 |
| យានយន្ត | 279,325,261 | 1,145,233,570 | 224,256,576 | 913,845,547 |
| ការដឹកជញ្ជូន | 211,051,304 | 865,310,346 | 178,264,117 | 726,426,277 |
| ផលិតកម្ម | 32,023,252 | 131,295,333 | 21,483,935 | 87,547,035 |
| ប្រើប្រាស់ផ្ទាល់ខ្លួន | 25,315,755 | 103,794,596 | 24,320,319 | 99,105,300 |
| សំណង់ | 27,104,132 | 111,126,942 | 19,512,099 | 79,511,803 |
| | **2,857,306,587** | **11,714,957,007** | **2,494,458,503** | **10,164,918,399** |

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក

*(ពីមុនជា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់)*

**កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបក្នុងគ្រាមិនបានធ្វើសវនកម្ម** (តពីទំព័រមុន)
នាថ្ងៃទី30 ខែកញ្ញា ឆ្នាំ2020 និងសម្រាប់ការិយបរិច្ឆេទបញ្ចប់ 9ខែ

## 6. ឥណទានផ្តល់ដល់អតិថិជន (តពីទំព័រមុន)

ក្រុមហ៊ុនបានទទួលស្គាល់សំវិធានធនលើ (ការកត់ត្រាបញ្ច្រាស់នៃ) ការខាតបង់បានរំពឹងទុកដូចខាងក្រោម៖

| | *សម្រាប់ការិយបរិច្ឆេទបញ្ចប់ 9ខែ នាថ្ងៃទី30 ខែកញ្ញា ឆ្នាំ2020 (មិនបានធ្វើសវនកម្ម)* | | *សម្រាប់ការិយបរិច្ឆេទបញ្ចប់ 9ខែ នាថ្ងៃទី30 ខែកញ្ញា ឆ្នាំ2019 (មិនបានធ្វើសវនកម្ម)* | |
|---|---|---|---|---|
| | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ 2.2)* | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ 2.2)* |
| សមតុល្យនៅធនាគារផ្សេងៗ | 22,878 | 93,475 | (28,015) | (112,871) |
| ឥណទានផ្តល់ដល់អតិថិជន | 29,774,299 | 121,479,369 | 11,630,382 | 47,151,874 |
| ប្រាក់កក់ដែលនឹងបង្វែរសងវិញ | 2,303 | 9,392 | 1,046 | 4,175 |
| | **29,799,480** | **121,582,236** | **11,603,413** | **47,043,178** |

| | *សម្រាប់ការិយបរិច្ឆេទបញ្ចប់ 3ខែ នាថ្ងៃទី30 ខែកញ្ញា ឆ្នាំ2020 (មិនបានធ្វើសវនកម្ម)* | | *សម្រាប់ការិយបរិច្ឆេទបញ្ចប់ 3ខែ នាថ្ងៃទី30 ខែកញ្ញា ឆ្នាំ2019 (មិនបានធ្វើសវនកម្ម)* | |
|---|---|---|---|---|
| | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ 2.2)* | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ 2.2)* |
| សមតុល្យនៅធនាគារផ្សេងៗ | 11,836 | 48,468 | 26 | 104 |
| ឥណទានផ្តល់ដល់អតិថិជន | 6,280,254 | 25,717,640 | 5,052,834 | 20,650,935 |
| ប្រាក់កក់ដែលនឹងបង្វែរសងវិញ | 318 | 1,303 | (677) | (2,767) |
| | **6,292,408** | **25,767,411** | **5,052,183** | **20,648,272** |

## 7. ទ្រព្យសកម្មផ្សេងៗ

| | *ថ្ងៃទី30 ខែកញ្ញា ឆ្នាំ2020 (មិនបានធ្វើសវនកម្ម)* | | *ថ្ងៃទី31 ខែធ្នូ ឆ្នាំ2019 (បានធ្វើសវនកម្ម)* | |
|---|---|---|---|---|
| | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ 2.2)* | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ 2.2)* |
| ប្រាក់បង់មុន | 2,484,313 | 10,185,683 | 8,250,706 | 33,621,626 |
| ប្រាក់កក់ | 553,408 | 2,268,973 | 429,170 | 1,748,868 |
| ការវិនិយោគរយៈពេលវែង | 28,167 | 115,485 | 28,167 | 114,781 |
| ផ្សេងៗ | 99,596 | 408,343 | 23,847 | 97,177 |
| | **3,165,484** | **12,978,484** | **8,731,890** | **35,582,452** |
| សំវិធានធនលើECLលើប្រាក់កក់ដែលនឹងបង្វែរសងវិញ | (11,144) | (45,690) | (8,841) | (36,027) |
| | **3,154,340** | **12,932,794** | **8,723,049** | **35,546,425** |

## 8. ទ្រព្យ និងបរិក្ខារ

*ថ្ងៃទី30 ខែកញ្ញា ឆ្នាំ2020*
*(មិនបានធ្វើសវនកម្ម)*

| | *គ្រឿងសង្ហារឹម* | *យានយន្ត* | *ទោចក្រយានយន្ត* | *កុំព្យូទ័រនិងបរិក្ខារបច្ចេកវិទ្យា* | *ការកែលម្អអគារ* | *បរិក្ខារទំនាក់ទំនង* | *ការងារកំពុងដំណើរការ* | *សរុប* |
|---|---|---|---|---|---|---|---|---|
| | *ដុល្លារអាមេរិក* | *ដុល្លារអាមេរិក* | *ដុល្លារអាមេរិក* | *ដុល្លារអាមេរិក* | *ដុល្លារអាមេរិក* | *ដុល្លារអាមេរិក* | *ដុល្លារអាមេរិក* | *ដុល្លារអាមេរិក* |
| **ថ្លៃដើម** | | | | | | | | |
| នាថ្ងៃទី01 ខែមករា ឆ្នាំ2020 | 4,871,906 | 2,917,904 | 354,528 | 7,171,805 | 2,297,202 | 417,766 | 86,160 | 18,117,271 |
| ទិញបន្ថែម | 422,858 | 137,490 | 6,150 | 513,095 | 43,354 | - | 1,462,880 | 2,585,827 |
| លក់ចេញ/លុបចេញពីបញ្ជី | (34,572) | (18,000) | - | (104,575) | (20,486) | - | - | (177,633) |
| ការផ្ទេរ | 48,310 | - | - | 578,041 | 78,415 | - | (704,766) | - |
| **នាថ្ងៃទី30 ខែកញ្ញា ឆ្នាំ2020** | **5,308,502** | **3,037,394** | **360,678** | **8,158,366** | **2,398,485** | **417,766** | **844,274** | **20,525,465** |
| **រំលស់បង្គរ** | | | | | | | | |
| នាថ្ងៃទី01 ខែមករា ឆ្នាំ2020 | 3,796,688 | 2,039,937 | 346,727 | 5,164,683 | 1,622,584 | 240,365 | - | 13,210,984 |
| រំលស់ | 347,796 | 228,153 | 2,187 | 842,371 | 145,050 | 37,411 | - | 1,602,968 |
| លក់ចេញ លុបចេញពីបញ្ជី និងផ្សេងៗ | (32,457) | (18,000) | - | (100,155) | (19,655) | - | - | (170,267) |
| **នាថ្ងៃទី30 ខែកញ្ញា ឆ្នាំ2020** | **4,112,027** | **2,250,090** | **348,914** | **5,906,899** | **1,747,979** | **277,776** | **-** | **14,643,685** |
| **តម្លៃពិតគណនេយ្យ** | | | | | | | | |
| **នាថ្ងៃទី30 ខែកញ្ញា ឆ្នាំ2020** | **1,196,475** | **787,304** | **11,764** | **2,251,467** | **650,506** | **139,990** | **844,274** | **5,881,780** |
| **សមមូលពាន់រៀល** *(កំណត់សម្គាល់ 2.2)* | **4,905,548** | **3,227,946** | **48,232** | **9,231,015** | **2,667,075** | **573,959** | **3,461,523** | **24,115,298** |

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក

*(ពីមុនជា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់)*

**កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបក្នុងគ្រាមិនបានធ្វើសវនកម្ម** (តពីទំព័រមុន)

នាថ្ងៃទី30 ខែកញ្ញា ឆ្នាំ2020 និងសម្រាប់ការិយបរិច្ឆេទបញ្ចប់ 9ខែ

## 8. ទ្រព្យ និងបរិក្ខារ (តពីទំព័រមុន)

| | *ថ្ងៃទី31 ខែធ្នូ ឆ្នាំ2019 (បានធ្វើសវនកម្ម)* | | | | | | | |
|---|---|---|---|---|---|---|---|---|
| | *គ្រឿងសង្ហារឹម* | *យានយន្ត* | *ទោចក្រយានយន្ត* | *កុំព្យូទ័រនិងបរិក្ខារបច្ចេកវិទ្យា* | *ការកែលម្អអគារ* | *បរិក្ខារទំនាក់ទំនង* | *ការងារកំពុងដំណើរការ* | *សរុប* |
| | *ដុល្លារអាមេរិក* | *ដុល្លារអាមេរិក* | *ដុល្លារអាមេរិក* | *ដុល្លារអាមេរិក* | *ដុល្លារអាមេរិក* | *ដុល្លារអាមេរិក* | *ដុល្លារអាមេរិក* | *ដុល្លារអាមេរិក* |
| **ថ្លៃដើម** | | | | | | | | |
| នាថ្ងៃទី01 ខែមករា ឆ្នាំ2019 | 4,479,429 | 2,764,687 | 346,328 | 6,287,673 | 2,139,004 | 300,453 | 151,409 | 16,468,983 |
| ទិញបន្ថែម | 328,267 | 290,781 | 8,200 | 664,102 | 65,554 | 56,145 | 713,400 | 2,126,449 |
| លក់ចេញ លុបចេញពីបញ្ជី | (136,279) | (143,396) | - | (86,013) | (75,741) | (36,732) | - | (478,161) |
| ការផ្ទេរ | 200,489 | 5,832 | - | 306,043 | 168,385 | 97,900 | (778,649) | - |
| **នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2019** | **4,871,906** | **2,917,904** | **354,528** | **7,171,805** | **2,297,202** | **417,766** | **86,160** | **18,117,271** |
| **រំលស់បង្គរ** | | | | | | | | |
| នាថ្ងៃទី01 ខែមករា ឆ្នាំ2019 | 3,443,046 | 1,800,234 | 341,651 | 4,232,064 | 1,458,904 | 234,972 | - | 11,510,871 |
| រំលស់ | 484,571 | 383,099 | 5,076 | 1,017,126 | 232,734 | 35,493 | - | 2,158,099 |
| លក់ចេញ លុបចេញពីបញ្ជី និងផ្សេងៗ | (130,929) | (143,396) | - | (84,507) | (69,054) | (30,100) | - | (457,986) |
| **ថ្ងៃទី31 ខែធ្នូ ឆ្នាំ2019** | **3,796,688** | **2,039,937** | **346,727** | **5,164,683** | **1,622,584** | **240,365** | **-** | **13,210,984** |
| **តម្លៃពិតគណនេយ្យ** | | | | | | | | |
| **នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2019** | **1,075,218** | **877,967** | **7,801** | **2,007,122** | **674,618** | **177,401** | **86,160** | **4,906,287** |
| **សមមូលពាន់រៀល** *(កំណត់សម្គាល់ 2.2)* | **4,381,513** | **3,577,716** | **31,789** | **8,179,022** | **2,749,068** | **722,909** | **351,103** | **19,993,120** |

## 9. សិទ្ធិក្នុងការប្រើប្រាស់ទ្រព្យសកម្ម

ក្រុមហ៊ុនបានជួលទីតាំងការិយាល័យ សម្រាប់ការិយាល័យកណ្តាល និងសាខា និងកន្លែងដាក់ ATM។ ព័ត៌មានអំពីកិច្ចសន្យាជួលដែលក្រុមហ៊ុនជាអ្នកជួលត្រូវបានបង្ហាញដូចខាងក្រោម៖

| | *ថ្ងៃទី30 ខែកញ្ញា ឆ្នាំ2020 (មិនបានធ្វើសវនកម្ម)* | | | |
|---|---|---|---|---|
| | *ការិយាល័យ* | *ទីតាំងATM* | *សរុប* | |
| | *ដុល្លារអាមេរិក* | *ដុល្លារអាមេរិក* | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ 2.2)* |
| **ថ្លៃដើម** | | | | |
| នាថ្ងៃទី1 ខែមករា ឆ្នាំ2020 | 20,863,158 | 500,461 | 21,363,619 | 87,056,750 |
| ទិញបន្ថែម | 4,250,787 | 207,530 | 4,458,317 | 18,279,100 |
| ការផុតកំណត់/ការបញ្ចប់ | (47,601) | (29,250) | (76,851) | (315,089) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | 534,087 |
| **នាថ្ងៃទី30 ខែកញ្ញា ឆ្នាំ2020** | **25,066,344** | **678,741** | **25,745,085** | **105,554,848** |
| **រំលស់បង្គរ** | | | | |
| ថ្ងៃទី1 ខែមករា ឆ្នាំ2020 | 6,722,452 | 280,902 | 7,003,354 | 28,538,670 |
| រំលស់ | 2,878,338 | 130,520 | 3,008,858 | 12,284,062 |
| ការផុតកំណត់/ការបញ្ចប់ | (30,491) | - | (30,491) | (124,466) |
